# ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០២៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអេស្កាប់ ដែលហៅកាត់ថា គ.ជ.អ.ស ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ដើម្បីសហប្រតិបត្តិការអន្តរជាតិ ក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក ២៧៥

១២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០២៩ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ជូនចំពោះអស់លោក ចំនួន ០៧ រូប ២៧៩

១២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៣០ ស្តីពីការតែងតាំង ឯកឧត្តម **មាស រដ្ឋា** ជាទីប្រឹក្សាក្រសួងការពារជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ២៨០

១២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៣១ ស្តីពីការតែងតាំងលោកជំទាវ **ស៊ុន សុគន្ធមាលា** ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ មានឋានៈស្មើ រដ្ឋលេខាធិការ ២៨១

១២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៣២ ស្តីពីការតែងតាំង ឯកឧត្តម **ខ្មៅ វីរៈ** ជាទីប្រឹក្សាក្រសួងការពារជាតិ មានឋានៈស្មើ រដ្ឋលេខាធិការ ២៨២

១២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៣៣ ស្តីពីការតែងតាំងលោកជំទាវ **មាស សុខគន្ធ** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ មានឋានៈស្មើ រដ្ឋលេខាធិការ ២៨៣

១២-០១-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០១០៩/០៣៤ ស្តីពីការប្រោសព្រះរាជទានចំពោះ ព្រះសង្ឃ. ឯកឧត្តម និងអស់លោក ចំនួន ០៣ រូប នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ២៨៤


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


០៩-០១-២០០៩ -អនុក្រឹត្យលេខ ១៤ អនក្រ.បក ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការប្តូរស្រុកសំពៅមាស ទៅជាក្រុងពោធិសាត់ នៃខេត្តពោធិសាត់ ២៨៥

០៩-០១-២០០៩ -អនុក្រឹត្យលេខ ១៥ អនក្រ.បក ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការប្តូរស្រុកស្ទឹងសែន ទៅជាក្រុងស្ទឹងសែន នៃខេត្តកំពង់ធំ ២៨៨
០៩-០១-២០០៩ -អនុក្រឹត្យលេខ ១៦ អនក្រ.បក ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការប្តូរស្រុកសិរីសោភ័ណ្ឌ ទៅជាក្រុង សិរីសោភ័ណ្ឌ នៃខេត្តបន្ទាយមានជ័យ ២៩១
០៩-០១-២០០៩ -អនុក្រឹត្យលេខ ១៧ អនក្រ.បក ស្តីពីការប្តូរស្រុកសំរោង ទៅជាក្រុងសំរោង នៃខេត្តឧត្តរមានជ័យ ២៩៤
១២-០១-២០០៩ -អនុក្រឹត្យលេខ ១៨ អនក្រ.បក ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី ១ ២៩៦
១២-០១-២០០៩ -អនុក្រឹត្យលេខ ១៩ អនក្រ.បក ស្តីពីការផ្តល់ឥណទានថវិកាសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ជូនទីស្តីការគណៈរដ្ឋមន្ត្រី ៣០៧
១២-០១-២០០៩ -អនុក្រឹត្យលេខ ២០ អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ៣០៩
១២-០១-២០០៩ -អនុក្រឹត្យលេខ ៣៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣២២
១២-០១-២០០៩ -អនុក្រឹត្យលេខ ៣៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣២៤
១២-០១-២០០៩ -អនុក្រឹត្យលេខ ៣៧ អនក្រ.តត ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៣២៥
១២-០១-២០០៩ -អនុក្រឹត្យលេខ ៣៨ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣២៧
១២-០១-២០០៩ -អនុក្រឹត្យលេខ ៣៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣២៩
១២-០១-២០០៩ -អនុក្រឹត្យលេខ ៤០ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៣៤០
១២-០១-២០០៩ -អនុក្រឹត្យលេខ ៤១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៤២
១២-០១-២០០៩ -អនុក្រឹត្យលេខ ៤២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៤៥
១២-០១-២០០៩ -អនុក្រឹត្យលេខ ៤៣ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣៤៨
១២-០១-២០០៩ -អនុក្រឹត្យលេខ ៤៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៥០
១២-០១-២០០៩ -អនុក្រឹត្យលេខ ៤៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៥១
១២-០១-២០០៩ -អនុក្រឹត្យលេខ ៤៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៥២
១២-០១-២០០៩ -អនុក្រឹត្យលេខ ៤៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៣
១២-០១-២០០៩ -អនុក្រឹត្យលេខ ៤៨ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៥៥
១២-០១-២០០៩ -អនុក្រឹត្យលេខ ៤៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៥៦

១២-០១-២០០៩ -អនុក្រឹត្យលេខ ៥០ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ ៣៥៨
១២-០១-២០០៩ -អនុក្រឹត្យលេខ ៥១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៦០
១២-០១-២០០៩ -អនុក្រឹត្យលេខ ៥២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៦១
១២-០១-២០០៩ -អនុក្រឹត្យលេខ ៥៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៦២

## ២.សេចក្តីសំរេច

១៣-០១-២០០៩ -សេចក្តីសំរេចលេខ ០៤ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៣៦៤

## III.ការងារបណ្តាក្រសួង

## ទីស្តីការក្រសួងមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៥-០១-២០០៩ -ប្រកាសលេខ ០៩៤ សហវ.ប្រក ស្តីពីការបន្ថែមសមាសភាពនៃគណៈកម្មាធិការដឹកនាំការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ៣៦៥

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០២៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិអេស្កាប់ ដែលហៅកាត់ថា គ.ជ.អ.ស ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាល ដើម្បីសហប្រតិបត្តិការអន្តរជាតិ ក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក។

ROYAUME DU CAMBODGE

LE MINISTRE DU PALAIS ROYAL

## ជំពូកទី ២
## សមាសភាព

**មាត្រា ២.-**

គណៈកម្មាធិការជាតិអេស្កាប់មានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| - ឥស្សរជនជាន់ខ្ពស់មួយរូប | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងផែនការ | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| - តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| - តំណាងក្រសួងបរិស្ថាន | សមាជិក |
| - តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| - តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| - តំណាងក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - តំណាងក្រសួងកិច្ចការនារី | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| - តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| - តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| - តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| - តំណាងក្រសួងសុខាភិបាល | សមាជិក |
| - តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| - តំណាងស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងបាងកក | សមាជិកអចិន្ត្រៃយ៍ |

**មាត្រា ៣.-**

គណៈកម្មាធិការជាតិអេស្កាប់ ដឹកនាំដោយប្រធានមានឋានៈចាប់ពីទេសរដ្ឋមន្ត្រីឡើងទៅ ជាអ្នកទទួលខុសត្រូវផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាល ។ សមាសភាពរបស់គណៈកម្មាធិការជាតិអេស្កាប់ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

## ជំពូកទី ៣

## តួនាទី និងភារកិច្ច

**មាត្រា ៤.-**

គណៈកម្មាធិការជាតិអេស្កាប់មានតួនាទីដូចខាងក្រោម ÷

- សិក្សាស្រាវជ្រាវលើប្រធានបទសេដ្ឋកិច្ច និងសង្គមកិច្ច នៅអាស៊ី និងប៉ាស៊ីហ្វិក ដែលពាក់ព័ន្ធនឹងព្រះរាជាណាចក្រកម្ពុជា
- ធ្វើទំនាក់ទំនងជាមួយគណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ច សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ "UN-ESCAP" ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងសង្គមកិច្ចកម្ពុជា
- សហការជាមួយក្រសួង ស្ថាប័នជាតិ និងអន្តរជាតិ អង្គការជាតិ និងអន្តរជាតិដែលពាក់ព័ន្ធ ដើម្បីដំណើរការការងារឱ្យមានភាពរលូន និងប្រកបដោយប្រសិទ្ធភាព
- ត្រៀងគរកមធ្យោបាយ និងធនធាន ដើម្បីរួមចំណែកក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ។

**មាត្រា ៥.-**

គណៈកម្មាធិការជាតិអេស្កាប់មានភារកិច្ចដូចខាងក្រោម ÷

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជូនរាជរដ្ឋាភិបាល
- សម្របសម្រួលជាមួយបណ្តាក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ព្រមទាំងអង្គការជាតិ អន្តរជាតិនានា
- រៀបចំកិច្ចប្រជុំនានាជាមួយគណៈកម្មការសេដ្ឋកិច្ច និងសង្គមកិច្ច សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ
- ចូលរួមប្រជុំថ្នាក់អន្តរជាតិនានា តាមការចាត់តាំងរបស់រាជរដ្ឋាភិបាល
- បំពេញភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន

## ជំពូកទី ៤

## ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិអេស្កាប់

**មាត្រា ៦.-**

គណៈកម្មាធិការជាតិអេស្កាប់មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអេស្កាប់ ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប ដែលមានឋានៈស្មើអគ្គលេខាធិការ អមដោយអគ្គលេខាធិការរងមួយចំនួន តាមការចាំបាច់ជាជំនួយការ ។

មាត្រា ៨.-

សមាជិកគណៈកម្មាធិការជាតិអេស្កាប់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

មាត្រា ៩.-

ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិអេស្កាប់ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១០.-

គណៈកម្មាធិការជាតិអេស្កាប់មានសិទ្ធិប្រើប្រាស់ត្រាដាច់ដោយឡែក ។

មាត្រា ១១.-

គណៈកម្មាធិការជាតិអេស្កាប់មានទីតាំងស្ថិតនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ១២.-

គណៈកម្មាធិការជាតិអេស្កាប់មានកញ្ចប់ថវិកាជាឧបសម្ព័ន្ធថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

គណៈកម្មាធិការជាតិអេស្កាប់មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ និងពីប្រភពផ្សេងទៀត សម្រាប់បំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

មាត្រា ១៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៤.-

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ១៥.-

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៩៧.០១០១.០២៦

លេខ : ៣០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩

ធិការរាជរដ្ឋាភិបាល

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៩*

ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០២៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ជូនចំពោះ ៖

១-លោក កាន់ ខេម៉ា
២-លោក អួន យ៉ង់
៣-លោក ឡូច សំបូរ
៤-លោក ខៀម ចែ
៥-លោក លី បុណ្យ
៦-លោក ស៊ូ ឡុងឌី
៧-លោក ដេង ចណ្ណា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩០១.០២៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩

លេខ : ៧២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៣០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហាគស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **មាស រដ្ឋា** ជាទីប្រឹក្សាក្រសួងការពារជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

៣៩ល.០៩០១.០៣០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩*

លេខៈ ៣៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមករា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

នស/រកត/០១០៩/០៣១

# ព្រះរាជក្រឹត្យ

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៤/១៧២ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាសភាពនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងលោកជំទាវ ស៊ុន សុគន្ធមាលា ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

*៣រ៧.០៩០១.០៣១*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩*

លេខ : ៣៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៣២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម ខៀវ វីរៈ ជាទីប្រឹក្សាក្រសួងការពារជាតិ មានឋានៈស្មើ រដ្ឋលេខាធិការ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.០៩០១.០៣២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩*

លេខ : ៣៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៣៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**.តែងតាំងលោកជំទាវ មាស សុខគន្ធ ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ២**.សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣**.ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៣៤ល.០៩០១.០៣៣*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩*

លេខ : ៣៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០១០៩/០៣៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

១- ព្រះមង្គលបញ្ញា សៅ តារាទី
២- ឯកឧត្តម ស៊ូរ ចាន់ធី
៣- លោក នូ ប៊ុនថា

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤.០៩០១.០៣៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩

លេខ : ៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ចិនកេន

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:..១៤...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលព្រំប្រទល់រដ្ឋបាល

## និងការប្តូរស្រុកសំពៅមាស ទៅជាក្រុងពោធិ៍សាត់ នៃខេត្តពោធិ៍សាត់

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាង ស្រុកសំពៅមាស និង ស្រុកកណ្តៀង ដោយកាត់យកឃុំកោះជុំ នៃស្រុកសំពៅមាស បញ្ចូលទៅក្នុងស្រុកកណ្តៀង ហើយកាត់យកឃុំបន្ទាយដី នៃស្រុកកណ្តៀង បញ្ចូលទៅក្នុងស្រុកសំពៅមាស នៃខេត្តពោធិ៍សាត់។

មាត្រា ២.-

ត្រូវបានប្តូរស្រុកសំពៅមាស ទៅជា **ក្រុងពោធិ៍សាត់** នៃខេត្តពោធិ៍សាត់ ។

ព្រំប្រទល់រដ្ឋបាលនៃ **ក្រុងពោធិ៍សាត់** ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ៣.-**

ត្រូវបានប្តូរឃុំចំនួនប្រាំពីរនៃ **ក្រុងពោធិ៍សាត់** ឱ្យទៅជាសង្កាត់ ដូចមានខាងក្រោម :

| | | |
|---|---|---|
| ១- ឃុំផ្ទះព្រៃ | ទៅជា | សង្កាត់ផ្ទះព្រៃ |
| ២- ឃុំលលកស | ទៅជា | សង្កាត់លលកស |
| ៣- ឃុំព្រៃញី | ទៅជា | សង្កាត់ព្រៃញី |
| ៤- ឃុំចំរើនផល | ទៅជា | សង្កាត់ចំរើនផល |
| ៥- ឃុំស្វាយអាត់ | ទៅជា | សង្កាត់ស្វាយអាត់ |
| ៦- ឃុំរលាប | ទៅជា | សង្កាត់រលាប |
| ៧- ឃុំបន្ទាយដី | ទៅជា | សង្កាត់បន្ទាយដី |

**មាត្រា ៤.-**

ត្រូវផ្ទេរទីតាំងសាលាស្រុកសំពៅមាស ដែលស្ថិតនៅក្នុងសង្កាត់ផ្ទះព្រៃ ទៅជា សាលា **ក្រុងពោធិ៍ សាត់** ។

**មាត្រា ៥.-**

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល **ក្រុងពោធិ៍សាត់** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តពោធិ៍សាត់ អភិបាលក្រុងពោធិ៍សាត់ អភិបាលស្រុកកណ្តៀង និង ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែមករា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..១៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការប្តូរស្រុកស្ទឹងសែន ទៅជាក្រុងស្ទឹងសែន នៃខេត្តកំពង់ធំ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាង ស្រុកស្ទឹងសែន ស្រុកសន្ទុក និង ស្រុកកំពង់ស្វាយ នៃខេត្តកំពង់ធំ ដោយកាត់យកឃុំចំនួនបីចេញពីស្រុកស្ទឹងសែន គឺ ឃុំត្បូងក្រពើ បញ្ចូលទៅក្នុងស្រុកសន្ទុក ឃុំក្ដីដូង និង ឃុំព្រៃគុយ បញ្ចូលទៅក្នុងស្រុកកំពង់ស្វាយ នៃខេត្តកំពង់ធំ។

**មាត្រា ២.-**

ត្រូវបានប្ដូរស្រុកស្ទឹងសែន ទៅជា ក្រុងស្ទឹងសែន នៃខេត្តកំពង់ធំ ។

ព្រំប្រទល់រដ្ឋបាលនៃ **ក្រុងស្ទឹងសែន** ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ៣.-**

ត្រូវបានប្ដូរ ឃុំចំនួនប្រាំបីនៃ **ក្រុងស្ទឹងសែន** ឱ្យទៅជាសង្កាត់ ដូចមានខាងក្រោម :

| | | |
|---|---|---|
| ១- ឃុំកំពង់រទេះ | ទៅជា | សង្កាត់កំពង់រទេះ |
| ២-ឃុំកំពង់ធំ | ទៅជា | សង្កាត់កំពង់ធំ |
| ៣- ឃុំដំរីជាន់ខ្លា | ទៅជា | សង្កាត់ដំរីជាន់ខ្លា |
| ៤-ឃុំអូរកន្ធរ | ទៅជា | សង្កាត់អូរកន្ធរ |
| ៥-ឃុំកំពង់ក្របៅ | ទៅជា | សង្កាត់កំពង់ក្របៅ |
| ៦-ឃុំព្រៃតាហ៊ូ | ទៅជា | សង្កាត់ព្រៃតាហ៊ូ |
| ៧-ឃុំអាចារ្យលាក់ | ទៅជា | សង្កាត់អាចារ្យលាក់ |
| ៨-ឃុំស្រយ៉ូវ | ទៅជា | សង្កាត់ស្រយ៉ូវ |

**មាត្រា ៤.-**

ត្រូវផ្ទេរទីតាំសាលាស្រុកស្ទឹងសែន ដែលស្ថិតនៅក្នុងសង្កាត់កំពង់រទេះ ទៅជាសាលា **ក្រុងស្ទឹងសែន** ។

**មាត្រា ៥.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល **ក្រុងស្ទឹងសែន** ត្រូវអនុលោមទៅតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តកំពង់ធំ អភិបាលក្រុងស្ទឹងសែន អភិបាលស្រុកសន្ទុក អភិបាលស្រុកកំពង់ស្វាយ និងក្រុមប្រឹក្សាឃុំ សង្កាត់ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលព្រំប្រទល់រដ្ឋបាល និងការប្តូរស្រុកសិរីសោភ័ណ ទៅជាក្រុងសិរីសោភ័ណ នៃខេត្តបន្ទាយមានជ័យ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាង ស្រុកសិរីសោភ័ណ និង ស្រុកព្រះនេត្រព្រះ នៃខេត្តបន្ទាយមានជ័យ ដោយកាត់យកឃុំមួយ គឺ ឃុំបុស្បូវ នៃស្រុកសិរីសោភ័ណ បញ្ចូលទៅក្នុងស្រុកព្រះនេត្រព្រះ នៃខេត្តបន្ទាយមានជ័យ ។

មាត្រា ២.-

ត្រូវបានប្តូរស្រុកសិរីសោភ័ណ ទៅជា **ក្រុងសិរីសោភ័ណ** នៃខេត្តបន្ទាយមានជ័យ ។

ព្រំប្រទល់រដ្ឋបាលនៃ **ក្រុងសិរីសោភ័ណ** ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធ នៃអនុក្រឹត្យ នេះ ។

មាត្រា ៣.-

ត្រូវបានប្តូរឃុំចំនួនប្រាំពីរនៃ **ក្រុងសិរីសោភ័ណ** ឱ្យទៅជាសង្កាត់ ដូចមានខាងក្រោម :

| | | |
|---|---|---|
| ១-ឃុំកំពង់ស្វាយ | ទៅជា | សង្កាត់កំពង់ស្វាយ |
| ២-ឃុំកោះពងសត្វ | ទៅជា | សង្កាត់កោះពងសត្វ |
| ៣-ឃុំម្កាក់ | ទៅជា | សង្កាត់ម្កាក់ |
| ៤-ឃុំអូរអំបិល | ទៅជា | សង្កាត់អូរអំបិល |
| ៥-ឃុំភ្នៀត | ទៅជា | សង្កាត់ភ្នៀត |
| ៦-ឃុំព្រះពន្លា | ទៅជា | សង្កាត់ព្រះពន្លា |
| ៧-ឃុំទឹកថ្លា | ទៅជា | សង្កាត់ទឹកថ្លា |

មាត្រា ៤.-

ត្រូវផ្ទេរទីតាំងសាលាស្រុកសិរីសោភ័ណ ដែលស្ថិតក្នុងសង្កាត់កំពង់ស្វាយ ទៅជាសាលា **ក្រុងសិរីសោភ័ណ** ។

មាត្រា ៥.-

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល **ក្រុងសិរីសោភ័ណ** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

មាត្រា ៦.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តបន្ទាយមានជ័យ អភិបាលក្រុងសិរីសោភ័ណ អភិបាលស្រុកព្រះនេត្រព្រះ និង ក្រុមប្រឹក្សាឃុំ សង្កាត់ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

  (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៧
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ




ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ព្រំប្រទល់ផែនទីបង្ហាញ ក្រុងសិរីសោភ័ណ

## ដែលត្រូវបានកាត់ឃុំមុស្សូ ឆាំងស្រុកចេញ

លេខ ...០០៩.ប.........

**បានឃើញ និង ឯកភាព**

ភ្នំពេញ, ថ្ងៃទី...០៦.៩...ខែ...ក.ក...ឆ្នាំ ២០០.៩...

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

វាស់វែង និង គូរដោយ

មន្ត្រីជំនាញនៃមន្ទីរ ផនសស.ខេត្ត

ធ្វើនៅ, ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០៨

មន្ត្រីជំនាញ

**ឈុន ឆុន**

លេខ: ០០៦ សរក

បានឃើញ និង ពិនិត្យត្រឹមត្រូវ

សិរីសោភ័ណ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៨

**អភិបាលស្រុក**

**អ៊ុំ រាត្រី**

លេខ: ០១/០៨ ផនសស.បជ/ផនស

បានឃើញ និង ពិនិត្យត្រឹមត្រូវលើពង្រាងគំនូសប្លង់

**សូមគោរពជូន**

ឯកឧត្តម អភិបាលខេត្ត មេត្តាពិនិត្យ សំរេច ដ៏ខ្ពង់ខ្ពស់ ។

បន្ទាយមានជ័យ, ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៨

**ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត**

វិស្វករសំណង់ បឺ សារី

លេខ: ០៥៧ ខបជ

បានឃើញ និង ឯកភាព

បន្ទាយមានជ័យ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៨

**អភិបាលខេត្ត**

**ញឹម វណ្ណដា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ..១៧..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្តូរស្រុកសំរោង ទៅជាក្រុងសំរោង នៃខេត្តឧត្តរមានជ័យ

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

### សម្រេច

**មាត្រា ១.-**

ត្រូវបានប្តូរស្រុកសំរោង ទៅជា **ក្រុងសំរោង** នៃខេត្តឧត្តរមានជ័យ ។

មាត្រា ២.-

ត្រូវបានប្តូរឃុំ ចំនួនប្រាំនៃ **ក្រុងសំរោង** ឱ្យទៅជាសង្កាត់ ដូចមានខាងក្រោម :

| | | |
|---|---|---|
| ១- ឃុំ បន្សាយរាក់ | ទៅជា | សង្កាត់ បន្សាយរាក់ |
| ២- ឃុំ បុស្សូរ | ទៅជា | សង្កាត់ បុស្សូរ |
| ៣- ឃុំ កូនគ្រៀល | ទៅជា | សង្កាត់ កូនគ្រៀល |
| ៤- ឃុំ សំរោង | ទៅជា | សង្កាត់ សំរោង |
| ៥- ឃុំ អូរស្មាច់ | ទៅជា | សង្កាត់ អូរស្មាច់ |

**មាត្រា ៣.-**

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល **ក្រុងសំរោង** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តឧត្តរមានជ័យ អភិបាលក្រុងសំរោង និង ក្រុមប្រឹក្សាសង្កាត់ដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

(ដើម្បីជូនជ្រាប)

- ដូចមាត្រា ៥
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...១៨...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី១

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## សម្រេច

**មាត្រា ១ .-** ត្រូវបានកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី និង សមាជិកក្រុមប្រឹក្សាខេត្តនីមួយៗ សម្រាប់អាណត្តិទី១ អនុលោមតាមមាត្រា១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ដែលរួមមាន ដូចខាងក្រោម ÷

| | | |
|---|---|---|
| ០១-រាជធានីភ្នំពេញ | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ០២-ខេត្ត កំពង់ចាម | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ០៣-ខេត្ត កណ្តាល | មានចំនួនសមាជិកក្រុមប្រឹក្សា | ២១ នាក់ |
| ០៤-ខេត្ត បាត់ដំបង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ០៥-ខេត្ត ព្រៃវែង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ០៦-ខេត្ត សៀមរាប | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ០៧-ខេត្ត តាកែវ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ០៨- ខេត្ត បន្ទាយមានជ័យ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៧ នាក់ |
| ០៩-ខេត្ត កំពង់ស្ពឺ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៧ នាក់ |
| ១០-ខេត្ត កំពង់ធំ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៧ នាក់ |
| ១១-ខេត្ត កំពត | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៧ នាក់ |
| ១២-ខេត្ត កំពង់ឆ្នាំង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ១៣-ខេត្ត ស្វាយរៀង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ១៤-ខេត្ត ពោធិ៍សាត់ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ១៥-ខេត្ត ក្រចេះ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ១៦-ខេត្ត ព្រះសីហនុ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ១៧-ខេត្ត កោះកុង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៣ នាក់ |
| ១៨-ខេត្ត ព្រះវិហារ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៣ នាក់ |
| ១៩-ខេត្ត រតនគិរី | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៣ នាក់ |
| ២០-ខេត្ត ស្ទឹងត្រែង | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៣ នាក់ |
| ២១-ខេត្ត ឧត្តរមានជ័យ | មានចំនួនសមាជិកក្រុមប្រឹក្សា | ១៣ នាក់ |
| ២២-ខេត្ត មណ្ឌលគិរី | មានចំនួនសមាជិកក្រុមប្រឹក្សា | ៩ នាក់ |
| ២៣-ខេត្ត ប៉ៃលិន | មានចំនួនសមាជិកក្រុមប្រឹក្សា | ៩ នាក់ |
| ២៤-ខេត្ត កែប | មានចំនួនសមាជិកក្រុមប្រឹក្សា | ៩ នាក់ |

មាត្រា ២ .- ត្រូវបានកំណត់ចំនួនសមាជិកក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌនីមួយៗ សម្រាប់អាណត្តិទី១ អនុលោមតាមមាត្រា១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមានដូចខាងក្រោម ÷

០១.រាជធានីភ្នំពេញ

| | | |
|---|---|---|
| ០១-ខណ្ឌ ដង្កោ | ចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ០២-ខណ្ឌ មានជ័យ | - ដ - | ១៩ នាក់ |
| ០៣-ខណ្ឌ ចំការមន | - ដ - | ១៩ នាក់ |
| ០៤-ខណ្ឌ ទួលគោក | - ដ - | ១៩ នាក់ |
| ០៥-ខណ្ឌ ឬស្សីកែវ | - ដ - | ១៩ នាក់ |
| ០៦-ខណ្ឌ ដូនពេញ | - ដ - | ១៧ នាក់ |
| ០៧-ខណ្ឌ ៧ មករា | - ដ - | ១៧ នាក់ |
| ០៨-ខណ្ឌ សែនសុខ | - ដ - | ១៧ នាក់ |

០២.ខេត្ត កំពង់ចាម

| | | |
|---|---|---|
| ០៩- ស្រុក ត្បូងឃ្មុំ | ចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ១០- ស្រុក ព្រៃឈរ | - ដ - | ១៩ នាក់ |
| ១១- ស្រុក មេមត់ | - ដ - | ១៩ នាក់ |
| ១២- ស្រុក ចំការលើ | - ដ - | ១៩ នាក់ |
| ១៣- ស្រុក ពញាក្រែក | - ដ - | ១៩ នាក់ |
| ១៤- ស្រុក ស្រីសន្ធរ | - ដ - | ១៩ នាក់ |
| ១៥- ស្រុក ស្ទឹងត្រង់ | - ដ - | ១៩ នាក់ |
| ១៦- ស្រុក កំពង់សៀម | - ដ - | ១៩ នាក់ |
| ១៧- ស្រុក បាធាយ | - ដ - | ១៩ នាក់ |
| ១៨- ស្រុក កងមាស | - ដ - | ១៩ នាក់ |
| ១៩- ស្រុក ក្រូចឆ្មារ | - ដ - | ១៩ នាក់ |

| | | |
|---|---|---|
| ២០- ស្រុក ជើងព្រៃ | - ដ - | ១៧ នាក់ |
| ២១- ស្រុក តំបែរ | - ដ - | ១៧ នាក់ |
| ២២- ស្រុក អូររាំងឪ | - ដ - | ១៧ នាក់ |
| ២៣- ស្រុក កោះសូទិន | - ដ - | ១៧ នាក់ |
| ២៤- ក្រុង កំពង់ចាម | - ដ - | ១៥ នាក់ |
| ២៥- ក្រុងសួង | - ដ - | ១៣ នាក់ |

## ០៣.ខេត្ត កណ្តាល

| | | |
|---|---|---|
| ២៦-ស្រុក កៀនស្វាយ | ចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ២៧-ស្រុក ស្អាង | - ដ - | ១៩ នាក់ |
| ២៨-ស្រុក កោះធំ | - ដ - | ១៩ នាក់ |
| ២៩-ស្រុក ខ្សាច់កណ្តាល | - ដ - | ១៩ នាក់ |
| ៣០-ស្រុក ពញាឮ | - ដ - | ១៩ នាក់ |
| ៣១-ស្រុក អង្គស្នួល | - ដ - | ១៩ នាក់ |
| ៣២-ស្រុក កណ្តាលស្ទឹង | - ដ - | ១៩ នាក់ |
| ៣៣-ស្រុក មុខកំពូល | - ដ - | ១៧ នាក់ |
| ៣៤-ស្រុក ល្វាឯម | - ដ - | ១៧ នាក់ |
| ៣៥-ស្រុក លើកដែក | - ដ - | ១៥ នាក់ |
| ៣៦-ក្រុង តាខ្មៅ | - ដ - | ១៥ នាក់ |

## ០៤.ខេត្ត បាត់ដំបង

| | | |
|---|---|---|
| ៣៧- ស្រុក ថ្មគោល | ចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ៣៨- ស្រុក មោងឫស្សី | - ដ - | ១៩ នាក់ |
| ៣៩- ស្រុក សង្កែ | - ដ - | ១៩ នាក់ |
| ៤០- ស្រុក បាណន់ | - ដ - | ១៧ នាក់ |
| ៤១- ស្រុក បវេល | - ដ - | ១៧ នាក់ |
| ៤២- ស្រុក ឯកភ្នំ | - ដ - | ១៧ នាក់ |
| ៤៣- ក្រុង បាត់ដំបង | - ដ - | ១៥ នាក់ |

| | | |
|---|---|---|
| ៤៤- ស្រុក ភ្នំព្រឹក | - ដ - | ១៥ នាក់ |
| ៤៥- ស្រុក កំរៀង | - ដ - | ១៥ នាក់ |
| ៤៦- ស្រុក រតនមណ្ឌល | - ដ - | ១៣ នាក់ |
| ៤៧- ស្រុក សំឡូត | - ដ - | ១៣ នាក់ |
| ៤៨- ស្រុក គាស់ក្រឡ | - ដ - | ១៣ នាក់ |
| ៤៩- ស្រុក រុក្ខគិរី | - ដ - | ១៣ នាក់ |
| ៥០- ស្រុក សំពៅលូន | - ដ - | ១១ នាក់ |

## ០៥.ខេត្ត ព្រៃវែង

| | | |
|---|---|---|
| ៥១-ស្រុក ពារាំង | ចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ៥២-ស្រុក ព្រះស្តេច | - ដ - | ១៩ នាក់ |
| ៥៣-ស្រុក កំពង់ត្របែក | - ដ - | ១៩ នាក់ |
| ៥៤-ស្រុក ស្វាយអន្ទរ | - ដ - | ១៩ នាក់ |
| ៥៥-ស្រុក មេសាង | - ដ - | ១៧ នាក់ |
| ៥៦-ស្រុក បាភ្នំ | - ដ - | ១៧ នាក់ |
| ៥៧-ស្រុក ស៊ីធរកណ្តាល | - ដ - | ១៧ នាក់ |
| ៥៨-ស្រុក កញ្ច្រៀច | - ដ - | ១៧ នាក់ |
| ៥៩-ស្រុក ពាមជរ | - ដ - | ១៧ នាក់ |
| ៦០-ស្រុក ពាមរក៍ | - ដ - | ១៥ នាក់ |
| ៦១-ស្រុក កំចាយមារ | - ដ - | ១៣ នាក់ |
| ៦២-ស្រុក កំពង់លាវ | - ដ - | ១៣ នាក់ |
| ៦៣-ក្រុង ព្រៃវែង | - ដ - | ១១ នាក់ |

## ០៦.ខេត្ត សៀមរាប

| | | |
|---|---|---|
| ៦៤-ស្រុក ជីក្រែង | ចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ៦៥-ស្រុក ពួក | - ដ - | ១៩ នាក់ |
| ៦៦-ស្រុក សូទ្រនិគម | - ដ - | ១៩ នាក់ |
| ៦៧-ស្រុក ប្រាសាទបាគង | - ដ - | ១៧ នាក់ |

| | | |
|---|---|---|
| ៦៨-ស្រុក ក្រឡាញ់ | - ដ - | ១៥ នាក់ |
| ៦៩-ស្រុក អង្គរជុំ | - ដ - | ១៥ នាក់ |
| ៧០-ក្រុង សៀមរាប | - ដ - | ១៣ នាក់ |
| ៧១-ស្រុក បន្ទាយស្រី | - ដ - | ១៣ នាក់ |
| ៧២-ស្រុក ស្រីស្នំ | - ដ - | ១៣ នាក់ |
| ៧៣-ស្រុក ស្វាយលើ | - ដ - | ១៣ នាក់ |
| ៧៤-ស្រុក វ៉ារិន | - ដ - | ១៣ នាក់ |
| ៧៥-ស្រុក អង្គរធំ | - ដ - | ១១ នាក់ |

## ០៧.ខេត្ត បន្ទាយមានជ័យ

| | | |
|---|---|---|
| ៧៦- ស្រុក មង្គលបូរី | ចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ៧៧- ស្រុក ព្រះនេត្រព្រះ | - ដ - | ១៧ នាក់ |
| ៧៨- ស្រុក អូរជ្រៅ | - ដ - | ១៥ នាក់ |
| ៧៩- ក្រុង សិរីសោភ័ណ | - ដ - | ១៥ នាក់ |
| ៨០- ស្រុក ភ្នំស្រុក | - ដ - | ១៥ នាក់ |
| ៨១- ស្រុក ស្វាយចេក | - ដ - | ១៥ នាក់ |
| ៨២- ក្រុង ប៉ោយប៉ែត | - ដ - | ១៣ នាក់ |
| ៨៣- ស្រុក ថ្មពួក | - ដ - | ១៣ នាក់ |
| ៨៤- ស្រុក ម៉ាឡៃ | - ដ - | ១៣ នាក់ |

## ០៨.ខេត្ត តាកែវ

| | | |
|---|---|---|
| ៨៥-ស្រុក បាទី | ចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ៨៦-ស្រុក ត្រាំកក់ | - ដ - | ១៩ នាក់ |
| ៨៧-ស្រុក សំរោង | - ដ - | ១៩ នាក់ |
| ៨៨-ស្រុក ទ្រាំង | - ដ - | ១៩ នាក់ |
| ៨៩-ស្រុក គីរីវង់ | - ដ - | ១៩ នាក់ |
| ៩០-ស្រុក ព្រៃកប្បាស | - ដ - | ១៩ នាក់ |
| ៩១-ស្រុក អង្គរបូរី | - ដ - | ១៥ នាក់ |
| ៩២-ស្រុក កោះអណ្តែត | - ដ - | ១៥ នាក់ |
| ៩៣-ក្រុង ដូនកែវ | - ដ - | ១៥ នាក់ |
| ៩៤-ស្រុក បុរីជលសារ | - ដ - | ១៣ នាក់ |

## ០៩.ខេត្ត កំពង់ស្ពឺ

| | | |
|---|---|---|
| ៩៥- ស្រុក បសេដ្ឋ | ចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ៩៦- ស្រុក គងពិសី | - ដ - | ១៩ នាក់ |
| ៩៧- ស្រុក ឧដុង្គ | - ដ - | ១៩ នាក់ |
| ៩៨- ស្រុក សំរោងទង | - ដ - | ១៩នាក់ |
| ៩៩- ស្រុក ភ្នំស្រួច | - ដ - | ១៧ នាក់ |
| ១០០- ស្រុក ថ្ពង | - ដ - | ១៥ នាក់ |
| ១០១- ក្រុង ច្បារមន | - ដ - | ១៥ នាក់ |
| ១០២- ស្រុក ឱរ៉ាល់ | - ដ - | ១៣ នាក់ |

## ១០.ខេត្ត កំពង់ធំ

| | | |
|---|---|---|
| ១០៣- ស្រុក បារាយណ៍ | ចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ១០៤- ស្រុក ស្ទោង | - ដ - | ១៩ នាក់ |
| ១០៥- ស្រុក កំពង់ស្វាយ | - ដ - | ១៧ នាក់ |
| ១០៦- ស្រុក សន្ទុក | - ដ - | ១៧ នាក់ |
| ១០៧- ស្រុក ប្រាសាទបល្ល័ង្គ | - ដ - | ១៥ នាក់ |
| ១០៨- ស្រុក ប្រាសាទសំបូរ | - ដ - | ១៥ នាក់ |
| ១០៩- ស្រុក សណ្តាន់ | - ដ - | ១៥ នាក់ |
| ១១០- ក្រុង ស្ទឹងសែន | - ដ - | ១៥ នាក់ |

## ១១.ខេត្ត កំពង់ឆ្នាំង

| | | |
|---|---|---|
| ១១១- ស្រុក រលាប្អៀរ | ចំនួនសមាជិកក្រុមប្រឹក្សា | ១៧ នាក់ |
| ១១២- ស្រុក កំពង់ត្រឡាច | - ដ - | ១៧ នាក់ |
| ១១៣- ស្រុក សាមគ្គីមានជ័យ | - ដ - | ១៧ នាក់ |
| ១១៤- ស្រុក កំពង់លែង | - ដ - | ១៥ នាក់ |
| ១១៥- ស្រុក បរិបូណ៌ | - ដ - | ១៥ នាក់ |
| ១១៦- ស្រុក ទឹកផុស | - ដ - | ១៥ នាក់ |
| ១១៧- ក្រុង កំពង់ឆ្នាំង | - ដ - | ១៣ នាក់ |
| ១១៨- ស្រុក ជលគីរី | - ដ - | ១៣ នាក់ |

### ១២.ខេត្ត កំពត

| | | |
|---|---|---|
| ១១៩- ស្រុក ទឹកឈូ | ចំនួនសមាជិកក្រុមប្រឹក្សា | ១៧ នាក់ |
| ១២០- ស្រុក កំពង់ត្រាច | - ដ - | ១៧ នាក់ |
| ១២១- ស្រុក ឈូក | - ដ - | ១៧ នាក់ |
| ១២២- ស្រុក បន្ទាយមាស | - ដ - | ១៧ នាក់ |
| ១២៣- ស្រុក អង្គរជ័យ | - ដ - | ១៧ នាក់ |
| ១២៤- ស្រុក ដងទង់ | - ដ - | ១៥ នាក់ |
| ១២៥- ស្រុក ជុំគីរី | - ដ - | ១៥ នាក់ |
| ១២៦- ក្រុង កំពត | - ដ - | ១៣ នាក់ |

### ១៣.ខេត្ត ស្វាយរៀង

| | | |
|---|---|---|
| ១២៧-ស្រុក រមាសហែក | ចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ១២៨-ស្រុក ស្វាយជ្រំ | - ដ - | ១៩ នាក់ |
| ១២៩-ស្រុក កំពង់រោទិ៍ | - ដ - | ១៥ នាក់ |
| ១៣០-ស្រុក រំដួល | - ដ - | ១៥ នាក់ |
| ១៣១-ស្រុក ស្វាយទាប | - ដ - | ១៥ នាក់ |
| ១៣២-ក្រុង ស្វាយរៀង | - ដ - | ១៥ នាក់ |
| ១៣៣-ស្រុក ចន្ទ្រា | - ដ - | ១៣ នាក់ |
| ១៣៤-ក្រុង បាវិត | - ដ - | ១១ នាក់ |

### ១៤.ខេត្ត ពោធិ៍សាត់

| | | |
|---|---|---|
| ១៣៥-ស្រុក បាកាន | ចំនួនសមាជិកក្រុមប្រឹក្សា | ១៩ នាក់ |
| ១៣៦-ស្រុក ក្រគរ | - ដ - | ១៧ នាក់ |
| ១៣៧-ក្រុង ពោធិ៍សាត់ | - ដ - | ១៥ នាក់ |
| ១៣៨-ស្រុក ភ្នំក្រវាញ | - ដ - | ១៥ នាក់ |
| ១៣៩-ស្រុក កណ្តៀង | - ដ - | ១៥ នាក់ |
| ១៤០-ស្រុក វាលវែង | - ដ - | ៧ នាក់ |

### ១៥.ខេត្ត កោះកុង

| | | |
|---|---|---|
| ១៤១-ក្រុង ខេមរភូមិន្ទ | ចំនួនសមាជិកក្រុមប្រឹក្សា | ១៣ នាក់ |
| ១៤២-ស្រុក បទុមសាគរ | - ដ - | ១១ នាក់ |

| | | |
|---|---|---|
| ១៤៣-ស្រុក ស្រែអំបិល | - ដ - | ១១ នាក់ |
| ១៤៤-ស្រុក មណ្ឌលសីមា | - ដ - | ៧ នាក់ |
| ១៤៥-ស្រុក គិរីសាគរ | - ដ - | ៧ នាក់ |
| ១៤៦-ស្រុក កោះកុង | - ដ - | ៧ នាក់ |
| ១៤៧-ស្រុក ថ្មបាំង | - ដ - | ៧ នាក់ |

## ១៦.ខេត្ត ក្រចេះ

| | | |
|---|---|---|
| ១៤៨-ស្រុក ព្រែកប្រសព្វ | ចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ១៤៩-ស្រុក ឆ្លូង | - ដ - | ១៥ នាក់ |
| ១៥០-ស្រុក សំបូរ | - ដ - | ១៥ នាក់ |
| ១៥១-ស្រុក ស្នួល | - ដ - | ១៥ នាក់ |
| ១៥២-ស្រុក ចិត្របុរី | - ដ - | ១៥ នាក់ |
| ១៥៣-ក្រុង ក្រចេះ | - ដ - | ១៣ នាក់ |

## ១៧.ខេត្ត ព្រះវិហារ

| | | |
|---|---|---|
| ១៥៤-ស្រុក រវៀង | ចំនួនសមាជិកក្រុមប្រឹក្សា | ១៣ នាក់ |
| ១៥៥-ស្រុក ជាំក្សាន្ត | - ដ - | ១១ នាក់ |
| ១៥៦-ស្រុក គូលែន | - ដ - | ១១ នាក់ |
| ១៥៧-ស្រុក ជ័យសែន | - ដ - | ១១ នាក់ |
| ១៥៨-ស្រុក សង្គមថ្មី | - ដ - | ១១ នាក់ |
| ១៥៩-ស្រុក ឆែប | - ដ - | ១១ នាក់ |
| ១៦០-ក្រុង ព្រះវិហារ | - ដ - | ១១ នាក់ |
| ១៦១-ស្រុក ត្បែងមានជ័យ | - ដ - | ៧ នាក់ |

## ១៨.ខេត្ត រតនគិរី

| | | |
|---|---|---|
| ១៦២-ក្រុង បានលុង | ចំនួនសមាជិកក្រុមប្រឹក្សា | ១៣ នាក់ |
| ១៦៣-ស្រុក អូរជុំ | - ដ - | ១១ នាក់ |
| ១៦៤-ស្រុក វើនសៃ | - ដ - | ១១ នាក់ |
| ១៦៥-ស្រុក បរកែវ | - ដ - | ១១ នាក់ |
| ១៦៦-ស្រុក លំផាត់ | - ដ - | ៧ នាក់ |

| | | |
|---|---|---|
| ១៦៧-ស្រុក កូនមុំ | - ដ - | ៧ នាក់ |
| ១៦៨-ស្រុក អណ្ដូងមាស | - ដ - | ៧ នាក់ |
| ១៦៩-ស្រុក អូរយ៉ាដាវ | - ដ - | ៧ នាក់ |
| ១៧០-ស្រុក តាវែង | - ដ - | ៧ នាក់ |

## ១៩.ខេត្ត ព្រះសីហនុ

| | | |
|---|---|---|
| ១៧១-ស្រុក ព្រៃនប់ | ចំនួនសមាជិកក្រុមប្រឹក្សា | ១៧ នាក់ |
| ១៧២-ក្រុង ព្រះសីហនុ | - ដ - | ១៥ នាក់ |
| ១៧៣-ស្រុក កំពង់សីលា | - ដ - | ១១ នាក់ |
| ១៧៤-ស្រុក ស្ទឹងហាវ | - ដ - | ៧ នាក់ |

## ២០.ខេត្ត ស្ទឹងត្រែង

| | | |
|---|---|---|
| ១៧៥-ស្រុក ថាឡាបរិវ៉ាត់ | ចំនួនសមាជិកក្រុមប្រឹក្សា | ១៣ នាក់ |
| ១៧៦-ក្រុង ស្ទឹងត្រែង | - ដ - | ១៣ នាក់ |
| ១៧៧-ស្រុក សេសាន | - ដ - | ១១ នាក់ |
| ១៧៨-ស្រុក សៀមប៉ាង | - ដ - | ៩ នាក់ |
| ១៧៩-ស្រុក សៀមបូក | - ដ - | ៧ នាក់ |

## ២១.ខេត្ត ឧត្ដរមានជ័យ

| | | |
|---|---|---|
| ១៨០-ក្រុង សំរោង | ចំនួនសមាជិកក្រុមប្រឹក្សា | ១៥ នាក់ |
| ១៨១-ស្រុក បន្ទាយអំពិល | - ដ - | ១៣ នាក់ |
| ១៨២-ស្រុក អន្លង់វែង | - ដ - | ១៣ នាក់ |
| ១៨៣-ស្រុក ត្រពាំងប្រាសាទ | - ដ - | ១៣ នាក់ |
| ១៨៤-ស្រុក ចុងកាល់ | - ដ - | ១១ នាក់ |

## ២២.ខេត្ត មណ្ឌលគិរី

| | | |
|---|---|---|
| ១៨៥-ស្រុក កែវសីមា | ចំនួនសមាជិកក្រុមប្រឹក្សា | ១១ នាក់ |
| ១៨៦-ស្រុក កោះញែក | - ដ - | ៧ នាក់ |
| ១៨៧-ស្រុក អូររាំង | - ដ - | ៧ នាក់ |
| ១៨៨-ស្រុក ពេជ្រាដា | - ដ - | ៧ នាក់ |
| ១៨៩-ក្រុង សែនមនោរម្យ | - ដ - | ៧ នាក់ |

២៣.ខេត្ត ប៉ៃលិន

| | | |
|---|---|---|
| ១៩០-ក្រុង ប៉ៃលិន | ចំនួនសមាជិកក្រុមប្រឹក្សា | ១៣ នាក់ |
| ១៩១-ស្រុក សាលាក្រៅ | - ដ - | ១៣ នាក់ |

២៤.ខេត្ត កែប

| | | |
|---|---|---|
| ១៩២-ស្រុក ដំណាក់ចង្អើរ | ចំនួនសមាជិកក្រុមប្រឹក្សា | ១១ នាក់ |
| ១៩៣-ក្រុង កែប | - ដ - | ៧ នាក់ |

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ...១៥...អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការផ្តល់ឥណទានថវិកា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ជូនទីស្តីការគណៈរដ្ឋមន្ត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៥ , ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ដោយអនុលោមទៅតាមមាត្រា ៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានអនុញ្ញាតផ្តល់ឥណទានថវិកា ចំនួន ៥០.០០០ លានរៀល (ហាសិបពាន់លានរៀល ) ទៅលើសៀវភៅថវិកា របស់ទីស្តីការគណៈរដ្ឋមន្ត្រីសំរាប់ការ គ្រប់គ្រង ឆ្នាំ ២០០៩ ។

**មាត្រា២:** ឥណទានថវិកាដូចមានក្នុងមាត្រា ១ ខាងលើ ត្រូវបានបន្ថែមនៅជំពូក ៦៥ សម្រាប់ឥណទានពិសេសនៅក្នុងខ្ទង់ចំណាយពិសេសរបស់រាជរដ្ឋាភិបាល ដើម្បីចំណាយក្នុងកិច្ចការប្រាសាទព្រះវិហារ ។ ការបញ្ជាចំណាយនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់នាយករដ្ឋមន្ត្រី ។

**មាត្រា៣:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាបេឡាករនៃឥណទានពិសេសនេះ។

**មាត្រា៤:** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជំរាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់បេសកកម្ម មុខងារ ភារកិច្ច និង ការរៀបចំរចនាសម្ព័ន្ធ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

## ជំពូកទី ២

## បេសកកម្ម ភារកិច្ច និង រចនាសម្ព័ន្ធ

**មាត្រា ២.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មានបេសកកម្មរៀបចំគោលនយោបាយ អនុវត្ត ជំរុញការអនុវត្ត និង តាមដានការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាល ស្របតាមគោលនយោបាយ និង យុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាល តាមការណែនាំ និង ការចង្អុលទិសរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។ ក្នុងបេសកកម្មនេះ អគ្គលេខាធិការដ្ឋាន មានតួនាទី និង ភារកិច្ចជាអាទិ៍ ៖

- ផ្តួចផ្តើមគំនិត សិក្សា និង លើកសំណើដាក់ជូនរាជរដ្ឋាភិបាល តាមរយៈប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល នូវទស្សនទាន គោលនយោបាយ ផែនការកម្ម និង កម្មវិធីកំណែទម្រង់រដ្ឋបាល
- អនុវត្ត សម្របសម្រួល និង ជំរុញ តាមដាន ត្រួតពិនិត្យ វាយតម្លៃលើកម្មវិធីកំណែទម្រង់រដ្ឋបាល ដែលបានដាក់ឱ្យអនុវត្ត ព្រមទាំងធ្វើរបាយការណ៍យ៉ាងទៀងទាត់ ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលនៃការអនុវត្តកម្មវិធីនោះ
- រៀបចំការដាក់ឱ្យដំណើរការ សម្របសម្រួល និង លើកសំណើដាក់ជូនរាជរដ្ឋាភិបាល តាមរយៈប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល នូវគម្រោងកំណែទម្រង់រដ្ឋបាល
- អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការដំឡើងប្រាក់បៀវត្សរ៍មូលដ្ឋានមន្ត្រីរាជការ
- ជួយសម្រួលដល់ការអនុវត្ត កម្មវិធីកំណែទម្រង់រដ្ឋបាល របស់បណ្តាក្រសួង ស្ថាប័ន តាមរយៈការរៀបចំ និងផ្សព្វផ្សាយនូវក្របខ័ណ្ឌគតិយុត្ត និង សេចក្តីណែនាំចាំបាច់នានា ដើម្បីពង្រឹងសមត្ថភាពអនុវត្ត និង ធ្វើឱ្យការងារកំណែទម្រង់រដ្ឋបាល មាននិរន្តរភាព
- ចូលរួមសហការ និង ធានានូវភាពរលូននៃដំណើរការ ការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាល

- អនុវត្តការកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

**មាត្រា ៣.-**

ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មានអគ្គលេខាធិការដ្ឋានមួយ ជាអង្គភាពប្រតិបត្តិ ដែលត្រូវបានដឹកនាំ និង គ្រប់គ្រងដោយអគ្គលេខាធិការ អមដោយអគ្គលេខាធិការរងមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៤.-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មានតួនាទី និង ភារកិច្ច ដូចតទៅ ៖

- បំពេញមុខងារទស្សនទាន ផែនការកម្ម ការដាក់ឱ្យដំណើរការ ការសម្របសម្រួល និង ការវាយតម្លៃលើគ្រប់គម្រោងដែលមាននៅក្នុងកម្មវិធីកំណែទម្រង់រដ្ឋបាល
- តាមដានត្រួតពិនិត្យ និង ធានាឱ្យមានភាពរលូន ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាល នៅតាមបណ្តាក្រសួង ស្ថាប័ន
- លើកសំណើជូនប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីពិនិត្យ និង សម្រេចលើការតែងតាំង ការដំឡើងឋានៈ ឋានន្តរស័ក្តិ និងថ្នាក់ ការផ្ទេរភារកិច្ច ឬ ការដកមុខតំណែងមន្ត្រី បុគ្គលិករបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- លើកសំណើជូនប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីជ្រើសរើសក្រុមជំនួយការបច្ចេកទេស និង លេខាធិការមួយចំនួន ជាជំនួយការប្រចាំថ្ងៃ ។

**មាត្រា ៥.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ត្រូវធ្វើការប្រជុំការងារយ៉ាងតិចមួយដង ក្នុងមួយខែ តាមការអញ្ជើញ និង ការណែនាំរបស់អគ្គលេខាធិការ ។

**មាត្រា ៦.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបំពេញការងាររបស់ខ្លួន ។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ប្រើប្រាស់មន្ត្រីរាជការមុខងារ

សាធារណៈ និង មានសិទ្ធិស្នើជូនប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ដើម្បីជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា តាមការចាំបាច់ ។

មន្ត្រីរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល អាចទទួលប្រាក់ឧបត្ថម្ភផ្សេងៗ ក្នុងក្របខ័ណ្ឌហិរញ្ញប្បទាន របស់ដៃគូអភិវឌ្ឍ ។

**មាត្រា ៨.-**

